

©UNICEF Cambodia/2017/Maria Svensson

# ការវាយតម្លៃលើគម្រោងសាកល្បង ផ្ទេរសាច់ប្រាក់ សម្រាប់ស្ត្រីមានផ្ទៃពោះ និងកុមារ នៅប្រទេសកម្ពុជា របស់ CARD និង UNICEF

*ខែមេសា ឆ្នាំ២០១៨*

ទីស្តីការគណៈរដ្ឋមន្ត្រី
ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (ក.ក.ជ.)

unicef
ដើម្បីកុមារគ្រប់រូប

# មាតិកា

សេចក្តីសង្ខេប ........................................ ២
វិធីសាស្ត្រវាយតម្លៃ ........................................ ៤
របកគម្ហើញនៃការវាយតម្លៃ ........................................ ៥
ភាពសមស្រប/ភាពពាក់ព័ន្ធ ........................................ ៥
ប្រសិទ្ធភាព ........................................ ៦
ប្រសិទ្ធផល ........................................ ៧
និរន្តភាព ........................................ ៧
សមធម៌ សមភាពយេនឌ័រ និង សិទ្ធិមនុស្ស ........................................ ៨
សេចក្តីសន្និដ្ឋាន ........................................ ៩
អនុសាសន៍ ........................................ ១១

# សេចក្តីសង្ខេប

ប្រទេសកម្ពុជាបានទទួលកំណើនសេដ្ឋកិច្ចដ៏រឹងមាំជាមធ្យមជាង 7 ភាគរយ ចាប់តាំងពីឆ្នាំ 2011 មក។ ទោះជាយ៉ាងណាទិន្នន័យភាពក្រីក្រឆ្នាំ 2015 បង្ហាញថាប្រជាជនកម្ពុជាប្រហែល 13,5 ភាគរយ រស់នៅក្រោមបន្ទាត់ភាពក្រីក្រ ។ លើសពីនេះទៅទៀត អាហាររូបត្ថម្ភបង្កជាបញ្ហាប្រឈមសម្រាប់ការអភិវឌ្ឍន៍ធនធានមនុស្សបច្ចុប្បន្ន និងអនាគតនៅក្នុងប្រទេស។ ខណៈភាពក្រេះក្រិនក្នុងចំណោមកុមារក្រោមអាយុ 5 ឆ្នាំ មានការធ្លាក់ចុះជាលំដាប់ (ផ្អែកតាមស្តង់ដារលូតលាស់កុមារ របស់អង្គការសុខភាពពិភពលោក ឆ្នាំ2006) បញ្ហាក្រេះក្រិននៅតែមានកម្រិតខ្ពស់ 32% បើយោងលើការស្ទង់មតិសុខភាពប្រជាសាស្ត្រកម្ពុជា(CDHS) ឆ្នាំ2014។ ដើម្បីឆ្លើយតបទៅនឹងបញ្ហាទាំងនេះ គម្រោងផ្ទេរសាច់ប្រាក់ ត្រូវបានអនុវត្តសាកល្បងដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (CARD) ដោយមានការគាំទ្របច្ចេកទេសពី អង្គការយូនីសេហ្វ ពីខែឧសភា ឆ្នាំ 2016 ដល់ខែវិច្ឆិកា ឆ្នាំ2017 នៅក្នុងឃុំចំនួនប្រាំបីក្នុងស្រុកប្រាសាទបាគង ក្នុងខេត្តសៀមរាប ដើម្បីដកចេញនូវឧបសគ្គហិរញ្ញវត្ថុ ធានាឲ្យគ្រួសារក្រីក្រទទួលបានសេវាសុខភាពនិងអាហាររូបត្ថម្ភកាន់តែប្រសើរឡើង។

## ប្រអប់ទី១: ទិដ្ឋភាពទូទៅនៃគម្រោង

**តំបន់គោលដៅ**
ស្រុកប្រាសាទបាគង
ឃុំចំនួន ៨ និងភូមិចំនួន ៥៧

**អ្នកទទួលផល**
ស្ត្រីមានផ្ទៃពោះ: ៥៩ នាក់
កុមារអាយុពី0-៥ឆ្នាំ: ១២៣៩នាក់

**ការផ្ទេរប្រាក់**
ប្រាក់គោល ៥$ក្នុង១ខែ
ប្រាក់រង្វាន់១០-១៤$/បំពេញលក្ខខ័ណ្ឌ១

**រយៈពេលគម្រោង**
ចាប់ផ្តើមពាក់កណ្តាលឆ្នាំ២០១៥
ការទូទាត់ដំបូងនៅខែឧសភា ២០១៦
គម្រោងបញ្ចប់នៅខែវិច្ឆិកា ២០១៧

**វដ្តនៃការអនុវត្ត**
ចំនួនវគ្គអប់រំ មាន៨វគ្គ
វដ្តនៃការទូទាត់មាន ៩វដ្ត

**ការចំណាយ**
ផ្ទេរទៅអ្នកទទួលផល US$ 109,344
កម្រៃអេអឹមខេ US$ 6,285
ប្រតិបត្តិការ US$ 73,760

គម្រោងសាកល្បងនេះ មានគោលបំណងលើកកម្ពស់ការប្រើប្រាស់សេវាសុខភាព និងអាហាររូបត្ថម្ភជាមូលដ្ឋានដល់ស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម 5ឆ្នាំ ដែលកំពុងរស់នៅក្នុងភាពក្រីក្រ។ គម្រោងនេះបង្កើតឡើងដើម្បីសាកល្បងលទ្ធភាព

ដែលអាចសម្រេចបាន នៃការផ្ទេរសាច់ប្រាក់ដោយប្រើរចនាសម្ព័ន្ធរដ្ឋាភិបាល ដែលមានស្រាប់ (រដ្ឋបាលថ្នាក់ក្រោមជាតិ) ដោយមិនចាំបាច់បង្កើតស្ថាប័នអនុវត្តពីខាងក្រៅ ។ ការជ្រើសរើសក្រុមគោលដៅត្រូវបានផ្អែកលើកម្មវិធី អត្តសញ្ញាណកម្មគ្រួសារក្រីក្រ (IDPoor) របស់រដ្ឋាភិបាលកម្ពុជា។ ការផ្ទេរសាច់ប្រាក់ត្រូវបានផ្តល់ដោយ អេអឹមខេ ដែលជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ខណៈដែលវគ្គអប់រំសុខភាព និងអាហាររូបត្ថម្ភសម្រាប់អ្នកចូលរួមគម្រោងត្រូវបានធ្វើឡើងដោយបុគ្គលិកមណ្ឌលសុខភាព។

ក្រុមគោលដៅអ្នកទទួលផលទទួលបានទាំងសាច់ប្រាក់រួមជាមួយវគ្គអប់រំស្តីពីសុខភាពមាតា និងទារក និង អាហាររូបត្ថម្ភរៀងរាល់ពីរខែម្តង។ ការផ្ទេរសាច់ប្រាក់រួមមាន សាច់ប្រាក់ជាមូលដ្ឋានចំនួន 5ដុល្លារ ក្នុងមួយខែដោយឥតល័ក្ខខ័ណ្ឌ រួមជាមួយនឹងការផ្ទេរប្រាក់រង្វាន់ សរុបរហូតដល់ចំនួន 90ដុល្លារក្នុងមួយឆ្នាំ។ ការទូទាត់ប្រាក់រង្វាន់ត្រូវបំពេញឲ្យបានតាមលក្ខខណ្ឌទាក់ទងនឹងឥរិយាបថស្វែងរកសុខភាព ដូចជាការពិនិត្យផ្ទៃពោះមុនសម្រាល ការសម្រាលកូននៅមណ្ឌលសុខភាពឬមន្ទីរពេទ្យ និងការពិនិត្យពោះក្រោយពេលសម្រាលកូន ការពិនិត្យតាមដានការលូតលាស់កម្ពស់ ការចាក់វ៉ាក់សាំងសម្រាប់កុមារអាយុក្រោម5ឆ្នាំ ហើយនឹងការចូលរួមវគ្គអប់រំសុខភាព និងអាហាររូបត្ថម្ភ ។

### គោលបំណងរួម គោលបំណងជាក់លាក់ និងវិសាលភាពនៃការវាយតម្លៃ

នៅខែកញ្ញាឆ្នាំ 2017 អង្គការយូនីសេហ្វប្រចាំប្រទេសកម្ពុជា ក្នុងនាម CARD បានចុះកិច្ចសន្យាជាមួយ IPE Global លីមីតធីត សហការជាមួយក្រុមហ៊ុន ឪអេស៊ីគ្រុប ខូអិលធី ដើម្បីអនុវត្តការវាយតម្លៃឯករាជ្យ សិក្សាលើគម្រោងសាកល្បង ផ្ទេរសាច់ប្រាក់របស់ CARD-UNICEF។ គោលបំណងនៃការវាយតម្លៃ គឺដើម្បីកំណត់នូវការអនុវត្តល្អៗ និងទាញមេរៀនពីគម្រោងសាកល្បង ផ្ទេរសាច់ប្រាក់ទាក់ទងនឹងលក្ខណៈវិនិច្ឆ័យ ភាពពាក់ព័ន្ធ ប្រសិទ្ធភាព ប្រសិទ្ធផល និរន្តរភាព និងសមធម៌ នៃការរៀបចំ និងការអនុវត្តគម្រោង។ ការវាយតម្លៃនេះក៏មានបំណងផ្តល់ព័ត៌មានសម្រាប់ការពង្រីកគម្រោងនេះ និងការរៀបចំកម្មវិធីផ្ទេរសាច់ប្រាក់ថ្នាក់ជាតិ សម្រាប់អនុវត្តទូទាំងប្រទេសដែលដឹកនាំដោយរាជរដ្ឋាភិបាលកម្ពុជា (RGC) ដូចបានចែងក្នុងក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម 2016-2025។

# វិធីសាស្ត្រវាយតម្លៃ

**ប្រអប់ទី២: ទំហំសំណាក**



**អង្កេត**

- អ្នកទទួលផល - 240;
- ស្វាមីរបស់អ្នកទទួលផល - 25;
- មិនមែនអ្នកទទួលផល - 23



**ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ**

- អ្នកពាក់ព័ន្ធសំខាន់ៗនៅថ្នាក់ជាតិ និងថ្នាក់ស្រុក- 22;
- ជនបង្គោលឃុំ- 8;
- មណ្ឌលសុខភាព- 4; ប្រធានភូមិ - 23



**ពិភាក្សាជាក្រុម**

- សមាជិកក្រុមប្រឹក្សាឃុំ - 8
- គ្រួសារអ្នកទទួលផល - 4

វិធីសាស្ត្រចម្រុះត្រូវបានអនុវត្តរួមបញ្ចូលគ្នារវាងការប្រមូលទិន្នន័យបឋមរបៀបបរិមាណ និងគុណភាព (សម្រាប់សម្ភាសន៍អ្នកទទួលផល អ្នកផ្តល់ព័ត៌មានសំខាន់ៗ ការពិភាក្សាជាក្រុម) រួមជាមួយនឹងការពិនិត្យឡើងវិញ លើឯកសារគម្រោងសំខាន់ៗ។ ទិដ្ឋភាពវិធីសាស្ត្រសំខាន់មួយនៃការវាយតម្លៃនេះ គឺការចូលរួមនិងការរៀនសូត្រ ពីអ្នកពាក់ព័ន្ធក្នុងការរៀបចំ និងដំណើរការវាយតម្លៃទាំងនៅថ្នាក់ជាតិ(ថ្នាក់ក្រសួង) និងថ្នាក់ក្រោមជាតិ(រដ្ឋបាលស្រុក ក្រុមប្រឹក្សាឃុំ មេភូមិ មណ្ឌលសុខភាព) រួមជាមួយដៃគូអនុវត្តន៍ (CARD និងយូនីសេហ្វ)។ ការវាយតម្លៃនេះធ្វើឡើងតាមលក្ខណៈវិនិច្ឆ័យរបស់គណៈកម្មាធិការជំនួយអភិវឌ្ឍន៍ នៃគណៈកម្មាធិការសហប្រតិបត្តិការអភិវឌ្ឍន៍ (DAC/OECD) ដោយផ្តោតលើ ភាពពាក់ព័ន្ធ ប្រសិទ្ធភាព ប្រសិទ្ធផល និង និរន្តរភាព។ សមធម៌ សមភាពយេនឌ័រនិងសិទ្ធិមនុស្ស ត្រូវបានបញ្ចូលជាវិស័យអាទិភាពរបស់យូនីសេហ្វ។

ការវាយតម្លៃបានជ្រើសរើសសំណាកភូមិចំនួន 23 នៅក្នុងស្រុកប្រាសាទបាគង ដែលមានតំណាងមកពីឃុំទាំងប្រាំបី។ ការជ្រើសរើសគំរូសំណាកដោយចៃដន្យនៃគ្រួសារចំនួន 240 ពីក្នុងតំបន់គោលដៅ ត្រូវបានធ្វើឡើងដើម្បីកាត់បន្ថយភាពលម្អៀងលើព័ត៌មានដែលទទួលបាន។ អ្នកទទួលផល ប្តីរបស់អ្នកទទួលផល មេគ្រួសារ និងអ្នកដែលមិនទទួលបានផល ត្រូវបានសម្ភាសនៅកម្រិតគ្រួសារ។ កិច្ចសម្ភាសន៍ជនបង្គោល និងការពិភាក្សាជាក្រុមត្រូវបានធ្វើឡើងនៅថ្នាក់ជាតិ ថ្នាក់ស្រុក ឃុំ និងកម្រិតគ្រួសារ (សូមមើលប្រអប់ទី២)។

# របកគំហើញនៃការវាយតម្លៃ

សេចក្តីសង្ខេបនៃលទ្ធផលសំខាន់ៗពីអន្តរកម្ម ជាមួយអ្នកផ្តល់ព័ត៌មានផ្សេងៗ ក៏ដូចជាការសង្កេតនៅមូលដ្ឋាននិងការពិនិត្យឡើងវិញលើឯកសារដែលមានស្រាប់ មានដូចខាងក្រោមៈ

## ភាពសមស្រប/ភាពពាក់ព័ន្ធ

គម្រោងសាកល្បងការផ្ទេរសាច់ប្រាក់ ត្រូវបានរកឃើញថាពាក់ព័ន្ធនឹងបរិបទរបស់ប្រទេសកម្ពុជា ទាក់ទងនឹងស្ថានភាពអាហារូបត្ថម្ភ និងសុខភាពរបស់ស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម 5ឆ្នាំ។ ការអនុលោមទៅតាមការទទួលខុសត្រូវ មានការពិបាកក្នុងការតាមដាន និងគ្មានភស្តុតាងដោយផ្ទាល់ ដើម្បីគាំទ្រដល់ប្រយោជន៍របស់ពួកគេ។ ជម្រើសទទួលបានសាច់ប្រាក់ប្រសើរជាង ជំនួយជាសំភារៈត្រូវបានអ្នកទទួលផល និងអ្នកអនុវត្ត ពេញចិត្ត។ គម្រោងសាកល្បងនេះពឹងផ្អែកលើ កម្មវិធីអត្តសញ្ញាណកម្មក្រីក្រ (IDPoor) របស់រាជរដ្ឋាភិបាលសម្រាប់កំណត់ក្រុមគោលដៅ។

ដូច្នេះដើម្បីទទួលបានការផ្ទេរសាច់ប្រាក់ លក្ខខ័ណ្ឌមួយគឺអ្នកទទួលផលត្រូវមានប័ណ្ណក្រីក្រ។ ដោយសារប្រព័ន្ធកម្មវិធីអត្តសញ្ញាណកម្មក្រីក្រ (IDPoor) នៅមានដែនកំណត់ បានធ្វើឲ្យការកំណត់អ្នកទទួលផល ក្នុងគម្រោងសាកល្បងផ្ទេរសាច់ប្រាក់នេះជួបប្រទះចំនុចខ្វះខាត ហើយនាំឲ្យគ្រួសារចំណាកស្រុក និងក្រុមងាយរងគ្រោះដទៃទៀត ត្រូវបានដកចេញ ហើយមិនទទួលបានប័ណ្ណក្រីក្រ។ ទោះបីជាមានការយឺតយ៉ាវដោយកង្វះឯកសារក៏ដោយ យន្តការចុះឈ្មោះអ្នកទទួលផល ប្រព្រឹត្តទៅធម្មតា និងរលូន។

ការវិភាគទិន្នន័យស្ទង់មតិបង្ហាញថា អ្នកទទួលផលភាគច្រើន បានប្រើប្រាស់សាច់ប្រាក់ពីគម្រោង ដើម្បីទិញម្ហូបអាហារ ហើយគម្រោងនេះបានជំរុញឱ្យមានឥរិយាបថស្វែងរកសេវាសុខភាព និងបង្កើនចំណេះដឹងអំពីអាហាររូបត្ថម្ភ។ ការអនុវត្តគម្រោងដោយគ្មានការបង្កើតស្ថាប័នអនុវត្តពីខាងក្រៅ ប៉ុន្តែប្រើរចនាសម្ព័ន្ធរដ្ឋដែលមានស្រាប់ (រដ្ឋបាលស្រុក និងឃុំ) ទទួលបានជោគជ័យ ប៉ុន្តែការត្រួតពិនិត្យលើលក្ខខ័ណ្ឌ ហើយយន្តការដោះស្រាយការតវ៉ា នៅមានកម្រិតនៅឡើយ ។ ទោះបីជាយ៉ាងណាក៏ដោយ ផ្នែកមួយចំនួនដូចជាការពិនិត្យតាមដាន និងការវាយតម្លៃ និងការបង្រៀនបច្ចេកទេសទំនាក់ទំនងដោយមានការចូលរួម ដល់បុគ្គលិកសុខាភិបាល ដើម្បីបង្រៀនបន្តវគ្គអប់រំគួរត្រូវពង្រឹងបន្ថែម។

អ្នកទទួលផលបានកោតសរសើរពីរយៈពេលនៃការផ្ទេរសាច់ប្រាក់ និងមានអារម្មណ៍ថាការផ្ទេរសាច់ប្រាក់ជួយដោះស្រាយតម្រូវការបន្ទាន់របស់ពួកគេ។ ទោះជាយ៉ាងណាអ្នកទទួលផលមានអារម្មណ៍ថាចំនួនទឹកប្រាក់គឺមិនគ្រប់គ្រាន់ដើម្បីដោះស្រាយតម្រូវការអាហាររូបត្ថម្ភទាំងអស់របស់ពួកគេទេ។

## ប្រសិទ្ធភាព

អ្នកទទួលផលនិងបុគ្គលិកថ្នាក់ក្រោមជាតិ បានរកឃើញថា គម្រោងផ្ទេរសាច់ប្រាក់មានប្រសិទ្ធភាពក្នុងការបង្កើនការប្រើប្រាស់សេវាសុខភាពមួយចំនួន ដូចជាការតាមដានការលូតលាស់របស់កុមារ និងការប្រើប្រាស់អាហារមានជីវជាតិ និងអាហារចម្រុះ។ អ្នកទទួលផលភាគច្រើនបានអះអាងថា ពួកគេបានប្រើប្រាក់លើអាហារជាពិសេសគ្រាប់ធញ្ញជាតិ និងត្រី។ ការបង្កើនចំណេះដឹងសុខភាពអាហាររូបត្ថម្ភអនាម័យ និងការថែទាំកុមារ។ ពាក់ព័ន្ធនឹងផលប៉ះពាល់អវិជ្ជមាន ពុំមានភស្តុតាងថាអ្នកទទួលផល ប្រើប្រាស់សាច់ប្រាក់ទៅទិញស្រា ឬបារី ឡើយ។ ផ្នែកដ៏សំខាន់មួយនៃភាពជោគជ័យនៃគម្រោងសាកល្បងផ្ទេរសាច់ប្រាក់ គឺការផ្លាស់ប្តូរឥរិយាបទតាមរយៈវគ្គអប់រំសុខភាព និងអាហារូបត្ថម្ភដែលត្រូវបានគេកោតសរសើរ ដោយមនុស្សគ្រប់គ្នា។ ដើម្បីអោយវគ្គអប់រំទាំងនេះកាន់តែមានប្រសិទ្ធភាព អ្នកទទួលផលគម្រោងបានណែនាំអោយប្រើប្រាស់វិធីសាស្ត្រដែលមានការចូលរួមកាន់តែច្រើនថែមទៀតត្រូវមានសម្ភារៈ រូបភាព និង ការផ្តល់ជូននូវអាហារសំរ៉ន់។ ការផ្តល់វគ្គអប់រំទាំងនេះនៅថ្ងៃបើកសាច់ប្រាក់ គឺទទួលបានការពេញចិត្តខ្លាំងពីអ្នកទទួលផលគម្រោង។ ប្រសិទ្ធភាពកាន់តែខ្លាំងថែមទៀត គឺចាំបាច់មានការផ្សព្វផ្សាយព័ត៌មាន តាមរយៈបណ្តាញផ្លូវការ ដូចជាផ្ទាំងរូបភាព ខិត្តប័ណ្ណ និងយុទ្ធនាការនានា។ ក្នុងករណីខ្លះការបណ្តុះបណ្តាលបុគ្គលិកថ្នាក់ក្រោម ធ្វើឡើងដោយខ្វះបច្ចេសទេសចូលរួម ដូច្នេះវគ្គទាំងនោះមួយចំនួនពុំសូវមានប្រសិទ្ធភាព។ ផ្នែកខ្លះទៀតត្រូវកែលម្អ ដើម្បីអោយគម្រោងកាន់តែមានប្រសិទ្ធភាព គឺជាការផ្តល់ការផ្ទេរប្រាក់រង្វាន់អោយទាន់ពេលវេលា។ ក្នុងអំឡុងពេលនៃគម្រោងសាកល្បង ការទូទាត់ប្រាក់រង្វាន់ភាគច្រើនត្រូវបានធ្វើឡើង សរុបក្នុងអំឡុងពេលនៃវគ្គទូទាត់ចុងក្រោយជាជាងការទូទាត់នៅវដ្តនីមួយៗ។ ភស្តុតាងពីកម្មវិធីផ្ទេរសាច់ប្រាក់ផ្សេងទៀត បង្ហាញថា ការផ្តល់សាច់ប្រាក់ទំហំធំ គឺមិនសូវត្រូវបានប្រើប្រាស់សម្រាប់ចំណាយអាហាររូបត្ថម្ភប្រចាំថ្ងៃនោះទេ។ ដំណើរការដោះស្រាយវិវាទ និងការត្រួតពិនិត្យ ដែលផ្នែកទាំងពីរនៅមានភាពខ្វះខាតក្នុងការអនុវត្តប្រកបដោយប្រសិទ្ធភាព។ មិនមានការរាយការណ៍អំពីពាក្យ

បណ្ដឹងផ្លូវការដែលត្រូវបានបញ្ជូន ប៉ុន្ដែមានតែការត្អូញត្អែរពាក្យសម្ដីមួយចំនួន។ ស្រដៀងគ្នានេះដែរ ការត្រួតពិនិត្យលម្អិត និង ក្របខ័ណ្ឌលទ្ធផល មិនត្រូវបានបង្កើតឡើង កំឡុងពេលការរៀបចំគម្រោងនោះទេ។ របកគំហើញពីគ្រប់ភាគីពាក់ព័ន្ធបង្ហាញថា ប្រព័ន្ធគ្រប់គ្រងព័ត៌មាន និង យន្ដការត្រួតពិនិត្យ ត្រូវពង្រឹងបន្ថែមទៀត។

## ប្រសិទ្ធផល

ការប្រើប្រាស់រចនាសម្ព័ន្ធរដ្ឋាភិបាលស្រាប់ ជាជាងពឹងផ្អែកលើការជួលបុគ្គលិកពីគម្រោងពីខាងក្រៅដែលមានតម្លៃខ្ពស់ បានជួយបង្កើនប្រសិទ្ធផលនៃគម្រោង។ ការផ្ទេរសាច់ប្រាក់មូលដ្ឋានដល់អ្នកទទួលផល ឲ្យបានទៀងទាត់ គឺជាជោគជ័យសំខាន់មួយនៃគម្រោងនេះ។ ការប្រើប្រាស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឯកភាជ្យ (AMK) បានជួយសម្រួលដល់ការផ្ទេរសាច់ប្រាក់តាមតម្រូវការ។ ការប្រើម៉ាស៊ីនឆូតកាត (POS) នៅកន្លែងបង់ប្រាក់ដែលទាមទារការភ្ជាប់អ៊ីនធឺណិត ស៊ីពេលក្នុងការទទួលបានសាច់ប្រាក់ ដូច្នេះហើយកាត់បន្ថយប្រសិទ្ធភាពនៃដំណើរការអនុវត្ត។ បញ្ហាប្រឈមដទៃទៀតដែលត្រូវបានកំណត់ រួមមានបញ្ហាហេដ្ឋារចនាសម្ព័ន្ធ ដូចជាសេវាដឹកជញ្ជូនសាធារណៈមិនល្អ ខ្វះហេដ្ឋារចនាសម្ព័ន្ធធនាគារនៅតាមជនបទ ការតភ្ជាប់អ៊ីនធឺណិតមិនប្រក្រតី និង បណ្ដាញទូរគមនាគមន៍នៅមានកម្រិត។

គម្រោងនេះកង្វះនូវវិធីសាស្ត្រជាផ្លូវការ ដើម្បីលើកកម្ពស់ការយល់ដឹងទាក់ទងនឹងការផ្ទេរសាច់ប្រាក់។ គម្រោងគួររៀបចំឲ្យកាន់តែល្អបន្ថែមទៀតលើរចនាសម្ព័ន្ធការគ្រប់គ្រងសំណុំរឿងបណ្ដឹង ក្របខ័ណ្ឌត្រួតពិនិត្យ និងប្រព័ន្ធគ្រប់គ្រងព័ត៌មាន។

## និរន្តភាព

គម្រោងសាកល្បងមានប្រយោជន៍ក្នុងការកំណត់ចំនុចខ្វះខាត និងភាពរាំងស្ទះ និង ការរៀបចំផែនទីបង្ហាញផ្លូវ ដើម្បីដោះស្រាយបញ្ហាអសកម្មទាំងនេះ ក្នុងការពង្រីកគម្រោង ឬអនុវត្តគម្រោងនាពេលអនាគត។ ភាពខ្វះចន្លោះដែលបានកំណត់ក្នុងគម្រោងសាកល្បង នេះអាចត្រូវបានកែសម្រួល ហើយភាគច្រើនតម្រូវឱ្យមានការចំណាយតែម្ដងដែលនឹងមានប្រសិទ្ធភាពក្នុងគម្រោងធំជាងនេះ។ ការពឹងផ្អែកលើរចនាសម្ព័ន្ធរបស់រដ្ឋាភិបាលមានស្រាប់ ជួយឲ្យគម្រោងកាន់តែមាននិរន្តរភាព។ ទោះយ៉ាងណាក៏ដោយ មានឧបសគ្គទាក់ទងនឹងសមត្ថភាពក្រុមប្រឹក្សាឃុំក្នុងការផ្ទេរសាច់ប្រាក់ និងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និង ទូរគមនាគមន៍ដែលមានសារៈសំខាន់សម្រាប់និរន្តរភាពគម្រោង។ ផ្នែកផ្សេងទៀតគួរពិចារណា ដូចជា

អត្រាអតិផរណា ការប្រែប្រួលអាកាសធាតុ និង ភាពធននឹងគ្រោះមហន្តរាយ ហើយនឹងរបបចំណីអាហារ ដើម្បីពង្រឹងនិរន្តភាពគម្រោង។ លើសពីនេះទៅទៀត ការពិគ្រោះយោបល់រវាងភាគីពាក់ព័ន្ធ បានបង្ហាញថាការសម្របសម្រួលជាមួយស្ថាប័ននានា រួមទាំងស្ថាប័នរដ្ឋាភិបាល ដូចជាក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា អ្នកបង្កើតប្រព័ន្ធព័ត៌មាន និងធនាគារក្នុងស្រុក ឬគ្រឹះស្ថានហិរញ្ញវត្ថុដទៃទៀត គឺជាការចាំបាច់សម្រាប់ការរៀបចំគម្រោងប្រកបដោយជោគជ័យ និង និរន្តរភាពក្នុងការអនុវត្តគម្រោងទាំងនោះ។

## សមធម៌ សមភាពយេនឌ័រ និង សិទ្ធិមនុស្ស

គម្រោងផ្ទេរសាច់ប្រាក់ត្រូវបានកំណត់ថា ម្ដាយ និងអាណាព្យាបាលជាអ្នកកាន់គណនីធនាគារ។ គណនីធនាគារដំបូងខ្លះត្រូវបានបើកនៅក្នុងនាមមេគ្រួសារជាបុរសដោយសារតែភាពមិនច្បាស់លាស់ក្នុងចំណោមអ្នកអនុវត្ត។ ទោះជាយ៉ាងណាក៏ដោយ ក្រោយមកគណនីទាំងអស់ត្រូវបានបើកនៅក្នុងនាមជាអាណាព្យាបាល ឬម្ដាយកុមារ។ អ្នកទទួលផលស្ទើរតែទាំងអស់បញ្ជាក់ថា ស្ត្រីភាគច្រើនសម្រេចចិត្តប្រើប្រាស់ប្រាក់ទាំងនោះ។ ចំណែកសារទាមទាឲ្យប្ដីចូលរួមសកម្មភាពគម្រោងស្មើគ្នា ពុំត្រូវបានបង្ហាញដោយអ្នកទទួលផល។ ហើយចំណែកប្ដីវិញ ភាគតិចណាស់ដែលបានឃើញជួយជូនប្រពន្ធទៅមណ្ឌលសុខភាព ហើយនឹងចូលរួមវគ្គអប់រំផ្សេងនឹងគិតថា ការងារទាំងអស់នេះសម្រាប់ប្រពន្ធ ក្នុងការថែទាំកូន និងផ្ទះសំបែង។ ពុំមានផលប៉ះពាល់អវិជ្ជមានណាមួយលើសង្គមត្រូវបានរកឃើញឡើយ។ ភាគច្រើននៃគ្រួសារមិនមែនអ្នកទទួលផល យល់និងទទួលយកហេតុផលដែលពុំបានបញ្ចូលក្នុងគម្រោង ហើយនិងពុំមានភាពអាក់អន់ចិត្តកើតឡើងដែរ។

គម្រោងនេះបង្ហាញថាមានសមធម៌ ដោយគ្មានការរើសអើងចំពោះការផ្ទេរសាច់ប្រាក់ និងឱកាសក្នុងការចូលរួមវគ្គអប់រំសុខភាព។ ទោះបីជាយ៉ាងណា គ្រួសារចំណាកស្រុក និង ក្រុមងាយរងគ្រោះដូចជា កុមារកំព្រា ពុំបានបញ្ចូលក្នុងកម្មវិធី។

# សេចក្តីសន្និដ្ឋាន

## ភាពពាក់ព័ន្ធ

- គម្រោងសាកល្បងនេះគឺស្របទៅតាមគោលដៅរបស់រាជរដ្ឋាភិបាលសម្រាប់កិច្ចគាំពារសង្គម និងយន្តការក្នុងការជ្រើសរើសក្រុមគោលដៅ គឺពាក់ព័ន្ធ។ ទោះបីជាយ៉ាងណា ក្រុមងាយរងគ្រោះពុំបានបញ្ចូលក្នុងកម្មវិធី។
- ការពង្រីកទៅកម្មវិធីជាតិគួរតែពិចារណាកាត់បន្ថយលក្ខខ័ណ្ឌ និងស្វែងរកវិធីសាស្ត្រដើម្បីធានាថាអ្នកទទួលផលមានឯកសារដែលត្រូវការទាំងអស់ជាមុន។
- គម្រោងនេះទទួលបានជោគជ័យ ក្នុងការប្រើប្រាស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

## ប្រសិទ្ធភាព

- ការផ្ទេរសាច់ប្រាក់មានប្រសិទ្ធភាពច្រើនក្នុងលក្ខខណ្ឌនៃការប្រើប្រាស់សាច់ប្រាក់។ ទំហំនៃការផ្ទេរសាច់ប្រាក់ គឺមិនគ្រប់គ្រាន់ ដើម្បីដោះស្រាយតម្រូវការអាហារូបត្ថម្ភ និងសុខភាពរបស់អ្នកទទួលផល។
- ការផ្ទេរសាច់ប្រាក់ ធ្វើឡើងទាន់ពេលវេលា ដោយគ្មានការលេចធ្លាយក្នុងការទូទាត់ ដោយប្រើប្រាស់គ្រឹះស្ថានខាងក្រៅ។
- ដើម្បីផ្លាស់ប្តូរឥរិយាបទត្រូវមានបច្ចេកទេសចូលរួម។
- ការត្រួតពិនិត្យការលួតលាស់ក្នុងចំណោមគ្រួសារអ្នកក្រីក្រត្រូវបានបញ្ជាក់។
- ការគ្រប់គ្រងនិងតាមដានករណី មានប្រសិទ្ធភាពតិចតួច និងមានចំណុចត្រូវកែលម្អ។

## ប្រសិទ្ធផល

- គម្រោងនេះត្រូវបានដំណើរការយ៉ាងរលូន និងមានប្រសិទ្ធភាព ជាមួយនឹងឧបសគ្គមួយចំនួន។
- បញ្ហាប្រឈមជាទូទៅត្រូវបានគេមើលឃើញថា មានការគ្រប់គ្រងប្រព័ន្ធគ្រប់គ្រងព័ត៌មាននិងការត្រួតពិនិត្យ និងការគ្រប់គ្រងករណីបណ្ដឹង។
- ការតភ្ជាប់អ៊ីនធឺណិតនៅតាមតំបន់ដាច់ស្រយាល ភូមិបណ្ដែតទឹក និងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យាសម្រាប់ត្រួតពិនិត្យ ត្រូវធ្វើឱ្យកាន់តែប្រសើរឡើងនៅថ្នាក់ក្រោមជាតិ ។

## និរន្តរភាព

- ការកំណត់កង្វះចន្លោះ ទាក់ទងការរៀបចំ និងការអនុវត្តគម្រោង អាចត្រូវបានកំណត់ដោយគ្មានការចំណាយច្រើន។
- ការប្រើប្រាស់ធនធានមនុស្សខាងក្នុងប្រកបដោយប្រសិទ្ធភាព និងមានប្រសិទ្ធផលក្នុងការអនុវត្តគម្រោង គឺជាជោគជ័យដ៏ធំធេង និងជាការបន្ថែមនូវនិរន្តរភាពយូរអង្វែងនៃគម្រោង។
- មិនមានបញ្ហាប្រឈមធ្ងន់ធ្ងរលើសមត្ថភាពជាទូទៅនៃបុគ្គលិកអនុវត្តគម្រោងសម្រាប់ការពង្រីកទៅថ្នាក់ជាតិ។
- ជារួម ដោយមានការវិនិយោគមួយចំនួនក្នុងការបង្កើនសមត្ថភាពធនធានមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធ គម្រោងនេះមានសក្ដានុពលជាគម្រោងកម្រិតថ្នាក់ជាតិ។

## សមធម៌

- ស្ត្រីគឺជាអ្នកកាន់កាប់គណនីសាច់ប្រាក់។
- ការចូលរួមរបស់បុរសនៅក្នុងគម្រោងផ្ទេរសាច់ប្រាក់ មិនមែនជាផ្នែកមួយនៃការរៀបចំគម្រោងនោះទេ។ ការបង្កើនចំណេះដឹង និងការអនុវត្តរបស់ស្វាមីមិនបានបង្ហាញដោយផ្ទាល់ទេ។
- មិនមានរបាយការណ៍ពីបញ្ហានានាពីមណ្ឌលសុខភាព ឬក្រុមប្រឹក្សាឃុំទេ ហើយគម្រោងគឺទទួលបានជោគជ័យដូចគ្នានៅគ្រប់ឃុំ។

# អនុសាសន៍

អនុសាសន៍ត្រូវបានបង្កើតឡើងដោយផ្អែកលើការរកឃើញពីការប្រមូលទិន្នន័យ និងការពិនិត្យឡើងវិញលើឯកសារ។ ធាតុចូល និងមតិយោបល់ត្រឡប់ពីភាគីពាក់ព័ន្ធទទួលបាននៅដំណាក់កាលជាច្រើន និងក្នុងកិច្ចពិភាក្សាជាច្រើន។ អនុសាសន៍ខាងក្រោមត្រូវបានបង្ហាញតាមលំដាប់លំដោយនៃអាទិភាពដោយផ្អែកលើការវាយតម្លៃ និងទស្សនៈរបស់ភាគីពាក់ព័ន្ធអំពីសារៈសំខាន់ និង ពេលវេលានៃសកម្មភាព។

| | |
|---|---|
| ទំហំសាច់ប្រាក់ត្រូវផ្ទេរ | អ្នកទទួលផលជាច្រើនបានរាយការណ៍ថាចំនួនទឹកប្រាក់នៃគម្រោងមិនគ្រប់គ្រាន់ដើម្បីបំពេញតាមតម្រូវការអាហារូបត្ថម្ភរបស់ពួកគេ។ ដូច្នេះទំហំនៃការផ្ទេរត្រូវការការវាយតម្លៃឡើងវិញនិងកែតម្រូវសម្រាប់អតិផរណា។ |
| ការអនុវត្តលក្ខខ័ណ្ឌ | ការបំពេញលក្ខខ័ណ្ឌរួមចំពោះការទូទាត់ប្រាក់រង្វាន់ត្រូវត្រួតពិនិត្យឡើងវិញ ដើម្បីធានា នូវប្រសិទ្ធភាព នៃការត្រួតពិនិត្យនិងចំណាយ។ លក្ខខណ្ឌគួរតែត្រូវបានកំណត់ត្រឹមតែវគ្គមានចូលរៀនវគ្គអប់រំសុខភាព ។ |
| យន្តការជ្រើសរើសក្រុមគោលដៅ | វិធីសាស្រ្តដែលមានសង្គតិភាពក្នុងការប្រើប្រាស់ IDPoor អាចបន្ត។ យ៉ាងណាក៏ដោយ យន្តការកំណត់ក្រុមគោលដៅជាក់លាក់នៃកម្មវិធីត្រូវមាន។ ការកំណត់ក្រុមគោលដៅតាមរយៈសហគមន៍ដែលគួរតែពិចារណាដើម្បីជ្រើសរើសគ្រួសារចំគោលដៅ។ |

| | |
|---|---|
| ការពង្រីកគម្រោង | ការពង្រីកគម្រោង គួរត្រូវពិចារណាលើឧបសគ្គសមត្ថភាពធនធានមនុស្សនិងថវិកា។ ការពង្រីកគម្រោងគួរធ្វើឡើងជាជំហ៊ានៗ។ ការជ្រើសរើសតំបន់គោលដៅ អាចផ្អែកលើកម្រិតភាពក្រីក្រ អត្រាកង្វះអាហារូបត្ថម្ភ និងការប្រើប្រាស់សេវាសុខភាព ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធ និងធនធានមនុស្ស។ |
| ការគ្រប់គ្រងប្រព័ន្ធព័ត៌មាន (MIS) | បង្កើត MIS ដ៏ទូលំទូលាយ និងអាចជឿជាក់បានដើម្បីកត់ត្រានូវទិន្នន័យអ្នកទទួលផល ក្នុងវដ្តជីវិតគម្រោងទាំងមូល។ ទម្រង់នៃការត្រួតពិនិត្យដោយដៃគួរតែត្រូវបានជំនួសដោយប្រព័ន្ធព័ត៌មាន។ |
| តួនាទី និងការទទួលខុសត្រូវ | តួនាទី និងការទទួលខុសត្រូវរបស់បុគ្គលិកថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវមានពិនិត្យឡើងវិញ។ សមត្ថភាពត្រូវធ្វើអោយប្រសើរឡើង ដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រតិបត្តិ ការផ្ទេរសាច់ប្រាក់ ជាពិសេសចំពោះសមាជិកក្រុមប្រឹក្សាឃុំ។ |
| សកម្មភាពដោយមានការចូលរួម | យុទ្ធនាការលើកកម្ពស់ការយល់ដឹង និងយុទ្ធនាការធ្វើសំបុត្រកំណើត ការផ្តល់កាតចាក់ថ្នាំបង្ការកុមារ អាចត្រូវបានចាប់ផ្តើមមុនពេលចាប់ផ្តើមដំណើរការចុះឈ្មោះចូលក្នុងគម្រោង។ |
| យន្តការដោះស្រាយបណ្តឹង | សម្រាប់គម្រោងផ្ទេរសាច់ប្រាក់កម្រិតថ្នាក់ជាតិ យន្តការដោះស្រាយបណ្តឹងច្បាស់លាស់ត្រូវមានដោយផ្អែកលើកម្រិតចំណេះដឹងរបស់អ្នកទទួលផល។ |

ASHISH MUKHERJEE AND KRITI GUPTA; IPE GLOBAL

ASSISTED BY CHEY TECH; DYNAMIC ALLIANCE CONSULTING (DAC) GROUP

FOR THE COMPLETE REPORT, PLEASE VISIT:

HTTPS://WWW.UNICEF.ORG/CAMBODIA/RESULTS_FOR_CHILDREN_27582.HTML

ទីស្តីការគណៈរដ្ឋមន្ត្រី
ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (ក.ស.ជ.)

unicef
ដើម្បីកុមារគ្រប់រូប